ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម

លេខ ✓ ព.ណ..........

# សេចក្តីថ្លែងការណ៍

## ឆ្លើយតបទៅនឹងសេចក្តីប្រកាសរបស់សហភាពអឺរ៉ុប ស្តីពីវិធានការ ការពារទីផ្សារដោយសហភាពអឺរ៉ុប មកលើអង្ករ ( Indica Rice ) នាំចេញពីកម្ពុជា

ក្រសួងពាណិជ្ជកម្ម បានពិនិត្យបទប្បញ្ញត្តិអនុវត្តលេខ(EU) ២០១៩/៦៧ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៩ របស់គណៈកម្មការអឺរ៉ុប និងចុះផ្សាយជាផ្លូវការ នៅថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៩ អំពីការដាក់វិធានការការពារទីផ្សារមកលើអង្ករ ( Indica Rice ) ដែលមានប្រភពដើមនៅកម្ពុជា និងមីយ៉ាន់ម៉ា។

ក្រសួងពាណិជ្ជកម្មកម្ពុជា សម្តែងនូវការសោកស្តាយចំពោះសេចក្តីសម្រេចនេះ ដែលមិនបានឆ្លុះបញ្ចាំងទាំងស្រុងលើទិដ្ឋភាពច្បាប់ពាណិជ្ជកម្មអន្តរជាតិ បទដ្ឋានបច្ចេកទេស និងសច្ចភាព ព្រមទាំងកិច្ចសហប្រតិបត្តិការកន្លងមកដ៏ល្អ រវាងរដ្ឋាភិបាល និងវិស័យឯកជន របស់កម្ពុជា និងសហគមន៍អឺរ៉ុប។ ក្នុងរយៈកាលជិត១៥ ឆ្នាំកន្លងមក ក្នុងនាមជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក *ការធ្វើពាណិជ្ជកម្មសរុប* រវាងកម្ពុជា-អឺរ៉ុបមានសន្ទុះរីកចម្រើនគួរជាទីមោទនៈ គឺកើនឡើងពីប្រមាណ ៩៤២លានដុល្លារអាមេរិក ក្នុងឆ្នាំ២០០៥ ទៅដល់ជាង៨,៤៤៣ពាន់លានដុល្លារអាមេរិក ជាមួយនឹងអត្រាកំណើនគិតជាមធ្យមធម្មតាប្រចាំឆ្នាំ (Annual-Simple Average Growth Rate) ប្រមាណ៦០%។ ជាមួយគ្នានេះ ភាគីទាំងពីរបានពិភាក្សា និងដោះស្រាយបញ្ហាទ្វេភាគីបានយ៉ាងល្អប្រសើរ តាមរយៈយន្តការនៃគណៈកម្មាធិការចម្រុះកម្ពុជា-អឺរ៉ុប ដែលបានប្រារព្ធធ្វើពីថ្ងៃទី១២-១៤ ខែមីនា ឆ្នាំ២០១៨ កន្លងទៅ នៅទីក្រុងព្រុចសែល ប្រទេសប៊ែលហ្ស៊ិក។ លទ្ធផលនៃកិច្ចសហប្រតិបត្តិការដ៏ល្អនេះ បានជួយដល់ពាណិជ្ជករ និងវិនិយោគិននៃសហគមន៍អឺរ៉ុប ឲ្យកាន់តែមានជំនឿទុកចិត្តក្នុងការចូលមកវិនិយោគ និងធ្វើពាណិជ្ជកម្មនៅកម្ពុជា ហើយពាណិជ្ជករ ជាពិសេស កសិករក្រីក្ររបស់កម្ពុជារាប់សែននាក់ ដែលបានទទួលចំណូលពីការនាំចេញអង្ករទៅកាន់សហគមន៍អឺរ៉ុប បានអបអរសាទរ និងលើកទឹកចិត្តឲ្យរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បន្តកិច្ចសហប្រតិបត្តិការល្អជាមួយសហភាពអឺរ៉ុប។

ការសម្រេចដាក់វិធានការការពារទីផ្សារដោយសហភាពអឺរ៉ុប មកលើអង្ករ ( Indica Rice ) ដែលមានប្រភពដើមមកពីកម្ពុជា មានឥទ្ធិពលគ្រប់គ្រាន់ សម្រាប់ដកហូតចំណូលរបស់ប្រជាកសិករក្រីក្រកម្ពុជា និងជាអាវុធសម្រាប់ធ្វើឃាតពួកគាត់ និងក្រុមគ្រួសារ ដែលកំពុងជាប់បំណុល ជាមួយនឹងស្ថាប័នឥណទាន ដែលបានផ្តល់ប្រាក់កម្ចីដល់ពួកគាត់។

ក្រសួងពាណិជ្ជកម្ម កំពុងពិនិត្យផ្ទៀងផ្ទាត់សេចក្តីសម្រេចនេះ ដោយផ្អែកលើទិដ្ឋភាពច្បាប់ និងវិធានពាណិជ្ជកម្មអន្តរជាតិ ដើម្បីបន្តធ្វើការតវ៉ាជាមួយនឹងសេចក្តីសម្រេច ដែលប្រជាជនកម្ពុជាយល់ថា ជាសេចក្តីសម្រេចដែលគ្មានសុក្រឹតភាព និងសច្ចភាពសង្គម និងសេដ្ឋកិច្ច។

ឆ្លៀតក្នុងឱកាសនេះ ក្រសួងពាណិជ្ជកម្មសូមចូលរួមជាមួយប្រជាជនកម្ពុជាប្រមាណ១៦លាននាក់ អំពាវនាវឲ្យគណៈកម្មការអឺរ៉ុបពិនិត្យឡើងវិញនូវការសម្រេចរបស់ខ្លួន ដោយផ្អែកលើវិធានពាណិជ្ជកម្មអន្តរជាតិ និងចំណងកិច្ចសហប្រតិបត្តិការល្អជាប្រពៃណី រវាងកម្ពុជា និងសហភាពអឺរ៉ុប។

ថ្ងៃព្រហស្បតិ៍ ១២កើត ខែបុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៩ ✓

ក្រសួងពាណិជ្ជកម្ម

ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារ: (៨៥៥)-២៣ ៨៦៦ ៤៦៩

Lot 19-61, Russian Fedention Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469